ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

លេខ..០៤០.០.ស.ស.ស

ថ្ងៃចន្ទ ៨រោច ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០

**ជម្រាបជូន**

**ឯកឧត្តម លោកជំទាវ អភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត**

**កម្មវត្ថុ:** ការបង្កើតគណៈកម្មការប្រយុទ្ធនឹងជំងឺ COVID-19 រាជធានី-ខេត្ត។

**យោង:** សេចក្តីសម្រេចលេខ ២៦ សសរ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២០ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ១៩ (COVID-19)។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តម លោកជំទាវ** មេត្តាជ្រាបថា តាមស្ថានភាពរីករាលដាលបច្ចុប្បន្ននៃជំងឺកូវីដ១៩ ដែលកំពុងរីករាលដាលជាសកល តម្រូវឲ្យមានសកម្មភាពឆ្លើយតបបន្ទាន់ទៅនឹងជំងឺនេះតាមការវិវត្តន៍នៃការរីករាលដាលនៃវីរុស ក្រសួងសុខាភិបាលស្នើសុំឲ្យឯកឧត្តម លោកជំទាវអភិបាលនៃគណៈអភិបាលរាជធានី-ខេត្តទាំងអស់ រៀបចំបង្កើតគណៈកម្មការប្រយុទ្ធនឹងជំងឺកូវីដ១៩ តាមរាជធានី-ខេត្ត របស់ខ្លួន ដែលមានសមាសភាពពីស្ថាប័ន មន្ទីរពាក់ព័ន្ធជុំវិញខេត្ត ហើយតម្រូវឱ្យឯកឧត្តម លោកជំទាវអភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត ទទួលបន្ទុកផ្ទាល់ជាប្រធាននៃគណៈកម្មការនេះ។

អាស្រ័យហេតុនេះ សូម **ឯកឧត្តម លោកជំទាវ** រៀបចំចាត់ចែង និងអនុវត្តឲ្យមានប្រសិទ្ធភាពខ្ពស់។

សូម ឯកឧត្តម លោកជំទាវអភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត ទទួលនូវការរាប់អានដ៏ស្មោះពីខ្ញុំ។

**រដ្ឋមន្ត្រីក្រសួងសុខាភិបាល**

**ម៉ម ប៊ុនហេង**

**ចម្លងជូន:**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- មន្ទីរសុខាភិបាលរាជធានី-ខេត្ត
- ឯកសារ-កាលប្បវត្តិ